សប្តាហ៍ទី
39

កូនចៀមវង្វេង

ព្រះយេស៊ូតាមរកកូនចៀមមួយក្បាលដែលវង្វេងបាត់រហូតទាល់តែឃើញ។
ដូចជាព្រះយេស៊ូ យើងស្រឡាញ់ និងយកចិត្តទុកដាក់ចំពោះមនុស្សដ៏មានតម្លៃ!

រឿងក្នុងព្រះគម្ពីរ

ព្រះយេស៊ូមានចៀមមួយរយក្បាល ប៉ុន្តែមានចៀមមួយក្បាលបានបាត់។

ព្រះយេស៊ូបានយាងទៅស្វែងរកចៀមដែលបាត់នោះ។ ព្រះអង្គមិនបានគេចពីផ្លូវដែលមានគ្រោះថ្នាក់នោះទេ។ ព្រះអង្គបានបីចៀមដែលនឿយហត់នោះនៅក្នុងព្រះហស្តរបស់ទ្រង់។

ព្រះអង្គមានអំណរជាខ្លាំងដែលបានរកឃើញកូនចៀមដែលបានវង្វេងនោះមកវិញ។

ព្រះយេស៊ូស្រឡាញ់យើងម្នាក់ៗខ្លាំងណាស់។

«រីឯព្រះបិតារបស់អ្នករាល់គ្នាដែលគង់នៅស្ថានបរមសុខ*ក៏ដូច្នោះដែរ ព្រះអង្គមិនសព្វព្រះហឫទ័យឲ្យអ្នកណាម្នាក់ក្នុងចំណោមអ្នកតូចតាចទាំងនេះវិនាសបាត់បង់ឡើយ»
(ម៉ាថាយ 18:14)



វត្ថុបំណង

- ដឹងពីក្តីស្រឡាញ់របស់ព្រះយេស៊ូដែលទ្រង់បានដើរកចៀមដែលបានវង្វេង
- បណ្តុះដួងចិត្តឱ្យចេះឱ្យតម្លៃ និងចេះយកចិត្តទុកដាក់លើមនុស្សម្នាក់ៗ
- លើកទឹកចិត្តដល់ការស្រមើស្រមៃ និងគំនិតច្នៃប្រឌិតតាមរយៈការធ្វើហត្ថកម្មបង្កើតចៀម
- ចែករំលែកសាច់រឿងព្រះគម្ពីរ បន្ទាប់ពីធ្វើសកម្មភាពរួច ហើយនឹងបណ្តុះដួងចិត្តអរព្រះគុណ។

សម្ភារៈ



របៀបធ្វើ

1. ប្រើថ្នាំពណ៌សតាមរបៀបផ្សេងៗគ្នា ដើម្បីបង្កើតជាធាមចៀមនៅលើចានក្រដាស។
2. កាតក្រដាសពណ៌ចេញជារូបមុខ និងត្រចៀកចៀមរួចបិទភ្ជាប់លើចានក្រដាស។
3. ប្រើហ្វឺតដើម្បីគូរភ្នែក ច្រមុះ និងមាត់រួចបន្ថែមថ្នាល់ពណ៌ផ្កាឈូក។
4. ធ្វើជើងដោយប្រើក្រដាសពណ៌ ហើយគូរក្រចកជើងដោយប្រើហ្វឺត។
5. ចោះប្រហោងតូចមួយនៅលើកែមចាន ហើយចងខ្សែ ដើម្បីអាចព្យួរចៀមបាន។
6. ចៀមដែលបានវង្វេងបាត់របស់អ្នកបានរួចរាល់ហើយ!



ការពង្រីកសកម្មភាព

- បង្កើតថ្នាំងខាងក្រោយធ្វើវាលស្មៅពណ៌បៃតង ហើយដាក់តាំងរូបចៀមរបស់អ្នក។
- លេងល្បែងស្វែងរកចៀមមួយក្នុងចំណោមចៀមកៅសិបប្រាំបួន។
- ធ្វើរូបតុក្កតាអាយ៉ងចៀម ហើយធ្វើសកម្មភាពសម្តែងដើរតួ។
- សម្តែងរឿងអំពីព្រះយេស៊ូស្វែងរកចៀមដែលវង្វេង។



Tip សម្រាប់គ្រូ

- ប្រើម្រាមដៃ សំឡីកាត់ត្រចៀក ឬអេប៉ុង ដើម្បីបង្កើតទម្រង់ធាមចៀមជាមួយថ្នាំពណ៌ស។
- សូមគូរមុខ និងជើងដោយប្រើហ្វឺត បន្ទាប់ពីថ្នាំពណ៌សួត ដើម្បីទទួលបានលទ្ធផលកាន់តែស្អាត។
- សូមលើកទឹកចិត្តកុមារឱ្យបង្ហាញការគុបតែងចៀមរបស់ពួកគេដោយសេរី និងប្រកបដោយភាពច្នៃប្រឌិត។
- បន្ទាប់ពីបញ្ចប់ការធ្វើសកម្មភាពហើយ សូមជួយឱ្យកុមារចងចាំពីក្តីស្រឡាញ់របស់ព្រះយេស៊ូ ដោយនិទានរឿងព្រះគម្ពីរឡើងវិញជាមួយគ្នា។

